បណ្ណព័ត៌មាន

# របៀបប្រលងយកអាជ្ញាបណ្ណបើកបររថយន្ត

## ការណែនាំសម្រាប់អ្នកមានអាជ្ញាបណ្ណបើកបរមកពីបរទេស

ដើម្បីប្រលងយកអាជ្ញាបណ្ណបើកបររថយន្ត ហើយបើកបរនៅក្នុងរដ្ឋវិចថូរៀបាន VicRoads តម្រូវឲ្យលោកអ្នកគោរពតាមច្បាប់បើកបរ ហើយអាចគ្រប់គ្រងរថយន្តបានដោយសុវត្ថិភាព។

### អ្នកកាន់ទិដ្ឋាការបណ្តោះអាសន្ន

បើសិនជាលោកអ្នកកាន់ទិដ្ឋាការបណ្តោះអាសន្នហើយបិតនៅក្នុងរដ្ឋវិចថូរៀ លោកអ្នកអាចបើករថយន្តបានដោយប្រើអាជ្ញាបណ្ណបើកបរមកពីបរទេស(អាជ្ញាបណ្ណនោះ គឺប្រាកដជាអាជ្ញាបណ្ណបច្ចុប្បន្ន ហើយមានសុពលភាព) ដោយមិនកំណត់ពេលវេលាឡើយ។ អាជ្ញាបណ្ណបើកបរមកពីបរទេសរបស់លោកអ្នកត្រូវតែសរសេរជាភាសាជាអង់គ្លេស(ឬក៏មានការបកប្រែជាភាសាអង់គ្លេស ឬក៏ជាអាជ្ញាបណ្ណបើកបរអន្តរជាតិ)។ បើលោកអ្នកសុំអាជ្ញាបណ្ណបើកបរក្នុងរដ្ឋវិចថូរៀ លោកអ្នកត្រូវប្រលងជាប់តេស្តដែលគេតម្រូវមក ហើយនៅពេលនោះ លោកអ្នកនឹងទទួលអាជ្ញាបណ្ណបើកបរមួយជាក់ជាមិនខាន។ អាជ្ញាបណ្ណបើកបរមកពីបរទេសរបស់លោកអ្នកគឺលែងមានសុពលភាពសម្រាប់ការបើកបរទៀតហើយ។

### អ្នកមានសិទ្ធិរស់នៅជាអចិន្ត្រៃយ៍

បើលោកអ្នកមានទិដ្ឋាការអចិន្ត្រៃយ៍រស់នៅក្នុងក្នុងរដ្ឋវិចថូរៀ លោកអ្នកអាចបើកបរបានដោយប្រើអាជ្ញាបណ្ណបើកបរមកពីបរទេស (អាជ្ញាបណ្ណនោះ គឺប្រាកដជាអាជ្ញាបណ្ណបច្ចុប្បន្ន ហើយមានសុពលភាព) សម្រាប់រយៈពេល៖

- 6 ខែចាប់ពីថ្ងៃដែលលោកអ្នកចូលមកក្នុងប្រទេសអូស្ត្រាលី (បើលោកអ្នកបានទទួលទិដ្ឋាការអចិន្ត្រៃយ៍នោះ មុនពេលដែលលោកអ្នកចូលមកក្នុងប្រទេសអូស្ត្រាលី) ឬ
- 6 ខែចាប់ពីថ្ងៃដែលលោកអ្នកបានទទួលទិដ្ឋាការអចិន្ត្រៃយ៍នោះ (បើលោកអ្នកបានទទួលទិដ្ឋាការអចិន្ត្រៃយ៍នោះ នៅក្នុងប្រទេសអូស្ត្រាលី)។

អាជ្ញាបណ្ណបើកបរមកពីបរទេសរបស់លោកអ្នកត្រូវតែសរសេរជាភាសាអង់គ្លេស(ឬក៏មានបកប្រែជាភាសាអង់គ្លេស ឬក៏អាជ្ញាបណ្ណបើកបរអន្តរជាតិ)។ បើលោកអ្នកចង់បន្តការបើកបរ ក្រោយពីរយៈពេល 6 ខែបានកន្លងផុតទៅ លោកអ្នកនឹងត្រូវការអាជ្ញាបណ្ណបើកបរចេញឲ្យដោយអាជ្ញាធររដ្ឋវិចថូរៀ។

**លោកអ្នកត្រូវតែមានអាយុ១៨ ឆ្នាំ ដើម្បីប្រលងយកអាជ្ញាបណ្ណរដ្ឋវិចថូរៀ។**

### ការប្រលងយកអាជ្ញាបណ្ណបើកបរនៅរដ្ឋវិចថូរៀ

ប្រទេសខ្លះមានស្តង់ដារអាជ្ញាបណ្ណបើកបរស្រដៀងគ្នាទៅនឹងប្រទេសអូស្ត្រាលី។ លោកអ្នកអាចប្តូរអាជ្ញាបណ្ណបើកបរបរទេសរបស់លោកអ្នកយកអាជ្ញាបណ្ណបើកបររដ្ឋវិចថូរៀ ដោយមិនចាំបាច់ប្រលងឡើយ ល្គឹកណាអាជ្ញាបណ្ណនោះជាអាជ្ញាបណ្ណបច្ចុប្បន្ន ឬមិនទាន់ហួសសុពលភាពលើសពី 5 ឆ្នាំ។ ដើម្បីឆែកមើលថាតើប្រទេសលោកអ្នកបិតនៅក្នុងបញ្ជីនៃប្រទេសទាំងនេះឬទេ សូមចុចប៊ូតុងនៅទីនេះ៖ **vicroads.vic.gov.au/OverseasDriversLicences**

សូមទូរស័ព្ទទៅលេខ 13 11 71 ឬអញ្ជើញទៅមណ្ឌលសេវាអតិថិជនរបស់ VicRoads ដើម្បីធ្វើការណាត់ជួបសុំយកអាជ្ញាបណ្ណបើកបររដ្ឋវិចថូរៀ។

បើអាជ្ញាបណ្ណបើកបររបស់លោកអ្នកមកពីប្រទេសដែលមិនបិតនៅក្នុងបញ្ជីដែលមានការទទួលស្គាល់ទេនោះ លោកអ្នកត្រូវតែប្រលងឲ្យជាប់៖

- ការធ្វើតេស្តតាមកុំព្យូទ័រដើម្បីស្ទង់មើលការយល់ដឹងអំពីច្បាប់បើកបរ, ហើយ
- ការធ្វើតេស្តតាមកុំព្យូទ័រដើម្បីស្ទង់មើលបញ្ញាយល់ដឹងរបស់លោកអ្នកពាក់ព័ន្ធនឹងគ្រោះថ្នាក់, ហើយ
- ការប្រលងបើកបររថយន្តនៅលើផ្លូវថ្នល់

ការធ្វើតេស្តទាំងនេះប្រព្រឹត្តទៅនៅមណ្ឌលសេវាអតិថិជនរបស់ VicRoads ហើយលោកអ្នកត្រូវតែធ្វើការណាត់ទុកជាមុន។ លោកអ្នកត្រូវតែប្រលងឲ្យជាប់តេស្តមួយសិន មុននឹងលោកអ្នកអាចប្រលងតេស្តមួយបន្ទាប់ទៀត។ លទ្ធផលនៃការធ្វើតេស្តមានសុពលភាពរយៈពេល 12 ខែ។ បើមិនទាន់មានការចេញអាជ្ញាបណ្ណឲ្យលោកអ្នកនៅក្នុងអំឡុងពេលនេះទេ លោកអ្នកត្រូវធ្វើតេស្តជាថ្មីទៀត។

### ការបកប្រែអាជ្ញាបណ្ណបើកបរ

បណ្ណអនុញ្ញាតបើកបរអន្តរជាតិ គឺអាចទទួលយកបានថាជាការបកប្រែក៏ប៉ុន្តែត្រូវមានអាជ្ញាបណ្ណបើកបរបរទេសអមជាមួយផង។

បើលោកអ្នកមិនមានបណ្ណអនុញ្ញាតបើកបរអន្តរជាតិ ហើយអាជ្ញាបណ្ណបើកបររបស់លោកអ្នកសរសេរជាភាសាបរទេសនោះ លោកអ្នកត្រូវតែភ្ជាប់ការកប្រែជាភាសាអង់គ្លេស ជាមួយនឹងច្បាប់ដើមនៃអាជ្ញាបណ្ណបើកបរភាសាបរទេសនេះ។ ការចំណាយលើការបកប្រែគឺជាការទទួលខុសត្រូវរបស់លោកអ្នក។

VicRoads ទទួលយកតែការបកប្រែដែលធ្វើឡើងដោយ៖

- អ្នកបកប្រែដែលមានសញ្ញាបត្រពី NAATI (កម្រិតណាក៏បាន), ឬ
- មន្ត្រីកុងស៊ុលសមស្របនៅក្នុងប្រទេសអូស្ត្រាលី, ឬ
- ការបកប្រែជាផ្លូវការមកពីប្រទេសកំណើត

បើលោកគ្មានអាជ្ញាបណ្ណបើកបរទេ លោកអ្នកអាចផ្តល់លិខិតមួយច្បាប់, ច្បាប់ដើមក៏បាន ច្បាប់ចម្លងក៏បាន ដោយមានការបញ្ជាក់ត្រឹមត្រូវមកពី៖

- អាជ្ញាធរផ្តល់អាជ្ញាបណ្ណបើកបរនៅក្នុងប្រទេសលោកអ្នក ដោយបញ្ជាក់នូវសេចក្តីពិស្តារនៃអាជ្ញាបណ្ណបើកបររបស់លោកអ្នក, ឬ
- ស្ថានកុងស៊ុលរបស់លោកអ្នក ដោយធ្វើការបញ្ជាក់នូវសេចក្តីលម្អិតនៃអាជ្ញាបណ្ណបើកបររបស់លោកអ្នក ជាមួយនឹងអាជ្ញាធរផ្តល់អាជ្ញាបណ្ណបើកបរនៅក្នុងប្រទេសលោកអ្នក។

## ការធ្វើតេស្តយកអាជ្ញាបណ្ណបើកបរ

### ការណាត់ពេលធ្វើតេស្ត

- ទូរស័ព្ទទៅលេខ 13 11 71
- លោកអ្នកនឹងត្រូវតែបង់ថ្លៃធ្វើតេស្ត នៅពេលដែលលោកអ្នកណាត់ពេលធ្វើតេស្ត
- បើការធ្វើតេស្តនេះពុំមានជាភាសារបស់លោកអ្នកទេនោះ ហើយលោកអ្នកចង់បានជំនួយភាសា VicRoads នឹងផ្តល់អ្នកបកប្រែជូនដោយមិនគិតថ្លៃឡើយ។ ដើម្បីរៀបចំអ្នកបកប្រែភាសា សូមអញ្ជើញទៅមណ្ឌលសេវាអតិថិជនរបស់VicRoads ។
- មន្ត្រីសេវាអតិថិជននឹងជម្រាបលោកអ្នកនូវអ្វីៗដែលលោកអ្នកត្រូវយកមកជាមួយនៅពេលប្រលងយកអាជ្ញាបណ្ណបើកបរ។

### ការមកប្រលង

- ត្រូវមកដល់ឲ្យបាន 10 នាទី មុននឹងការធ្វើតេស្តចាប់ផ្តើម។
- យកមកជាមួយនូវអ្វីៗគ្រប់យ៉ាងដែលជាការតម្រូវចាំបាច់សម្រាប់ការប្រលងនេះ។
- យកមកជាមួយនូវអាជ្ញាបណ្ណមកពីបរទេស ជាមួយនឹងសេចក្តីបកប្រែបើសិនជាមានការតម្រូវ(សូមមើលផ្នែកស្តីពីការបប្រែអាជ្ញាបណ្ណ)។
- បើលោកអ្នកមកយឺត ឬក៏មិនបានផ្តល់នូវឯកសារត្រឹមត្រូវ លោកអ្នកនឹងមិនអាចចូលប្រលងបានឡើយ។

## ការធ្វើតេស្តតាមកុំព្យូទ័រដើម្បីស្ទង់មើលការយល់ដឹងអំពីច្បាប់បើកបរ

ដើម្បីត្រៀមខ្លួនសម្រាប់ការប្រលង លោកអ្នកគួរតែបានអានសៀវភៅពន្យល់អំពីក្បួនបើកបរតែឯង(Road to Solo Driving) ដើម្បីឲ្យបានយល់ដឹងអំពីច្បាប់បើកបរ។ លោកអ្នកអាចមើលសៀវភៅនេះតាមអ៊ិនធើរណិត: **vicroads.vic.gov.au**. ។ សៀវភៅនេះមានជូនជាភាសាអង់គ្លេស ចិន (កុកងឺ) វៀតណាម ទួរគី និងអារ៉ាប់។

ការប្រលងមានជូនជាភាសាដូចខាងក្រោម៖

| | | |
|---|---|---|
| អាល់បានី | ម៉ាសេដូនី | សូម៉ាលី |
| អារ៉ាប់ | ជីស្វិន | អេស្ប៉ាញ |
| ខ្មែរ | រុស្ស៊ី | ទួរគី |
| ចិន | ស៊ែប | វៀតណាម |
| អង់គ្លេស | ស៊ិង្ហាលី | |

លោកអ្នកអាចហាត់រៀនធ្វើតេស្តជាភាសាអង់គ្លេសនៅឯ **vicroads.vic.gov.au**

### ការធ្វើតេស្តអំពីការយល់ដឹង៖

- ធ្វើការវាយតម្លៃការយល់ដឹងរបស់លោកអ្នកអំពីច្បាប់បើកបរនិងការទទួលខុសត្រូវរបស់លោកអ្នកក្នុងឋានៈជាអ្នកបើករ ហើយការធ្វើតេស្តនេះគឺផ្អែកទៅលើសៀវភៅក្បួនបើកបរតែឯង(Road to Solo Driving handbook) ។
- មាន 32 សំណួរ ហើយដើម្បីឲ្យជាប់ លោកអ្នកត្រូវទទួលពិន្ទុយ៉ាងតិច 78% ។

សម្រាប់ព័ត៌មានបន្ថែម សូមបើកមើលវិបសាយថ៍ **vicroads.vic.gov.au** ឬទូរស័ព្ទទៅលេខ៖ **13 11 71** ឬ អញ្ជើញទៅជួបមណ្ឌលសេវាអតិថិជនរបស់ VicRoads ។

ព័ត៌មានដែលផ្តល់ជូននៅក្នុងបណ្ណព័ត៌មាននេះ គឺត្រឹមត្រូវនៅពេលបោះពុម្ពផ្សាយ ហើយខ្លឹមសារនៃព័ត៌មាននេះអាចមានការផ្លាស់ប្តូរ។

## ការធ្វើតេស្តតាមកុំព្យូទ័រដើម្បីស្ទង់មើលបញ្ញាយល់ដឹងរបស់លោកអ្នកពាក់ព័ន្ធនឹងគ្រោះថ្នាក់

### តេស្តស្ទង់មើលបញ្ញាយល់ដឹងពាក់ព័ន្ធនឹងគ្រោះថ្នាក់៖

- ធ្វើការវាយតម្លៃថា លោកអ្នកអាចមើលដឹងហើយឆ្លើយតបទៅនឹងស្ថានភាពចរាចរណ៍ខុសៗគ្នា មានដូចជារថយន្ត អ្នកថ្មើរជើង និងអ្នកជិះកង់ជាដើម។
- រួមមានការថតវីដេអូខ្លីៗ ទៅតាមទស្សនៈយល់ឃើញរបស់អ្នកបើកបរ។ លោកអ្នកត្រូវតែបង្ហាញពីពេលដែលលោកអ្នកនឹងបញ្ចេញប្រតិកម្មបើសិនជាលោកអ្នកជាអ្នកបើកបរ (ឧ. បន្ថយល្បឿន ឬចាប់ផ្តើមបត់)។
- ការឆ្លើយតបរបស់លោកអ្នកនឹងត្រូវគេវាយតម្លៃ ក្នុងក្របខណ្ឌសុវត្ថិភាព។
- លោកអ្នកនឹងមានពេល 45 នាទី សម្រាប់ការធ្វើតេស្តនេះ។
- លោកអ្នកអាចធ្វើតេស្តស្ទង់មើលបញ្ញាយល់ដឹងពាក់ព័ន្ធនឹងគ្រោះថ្នាក់ ជាភាសាណាមួយក៏បាននៅក្នុងចំណោមភាសាទាំងឡាយដូចដែលមានរាយជូននៅក្នុងបញ្ជីខាងលើ។

## ការធ្វើតេស្តបើកបរលើផ្លូវថ្នល់

តេស្តបើកបរជួយវាយតម្លៃសមត្ថភាពរបស់លោកអ្នកក្នុងការបើកបរដោយសុវត្ថិភាព។ លោកអ្នកត្រូវតែ៖

- បើកបរដោយសុវត្ថិភាព
- គ្រប់គ្រងរថយន្តបានដោយរលូន
- គោរពច្បាប់បើកបរ
- សហការជាមួយនឹងអ្នកប្រើប្រាស់ផ្លូវថ្នល់ដទៃទៀត

### តេស្តបើកបរ៖

- រួមមានការឆែកពិនិត្យមុនពេលបើកបរ និងការបើកបរ២ដំណាក់កាល។
- លោកអ្នកនឹងចូលទៅដំណាក់កាលទីពីរ បើសិនជាលោកអ្នកជាប់តេស្តដំណាក់កាលទីមួយ។
- ដំណាក់កាលទីមួយ គឺជាការបើកបរនៅក្នុងស្ថានភាពចរាចរណ៍ដែលមិនសូវសម្បូររថយន្ត សម្រាប់រយៈពេល10 នាទី។ ដំណាក់កាលទីពីរ គឺជាការបើកបរនៅក្នុងស្ថានភាពចរាចរណ៍មមាញឹកសម្រាប់រយៈពេល 20 នាទី។

### អ្នកត្រូវតែនាំយកមកជាមួយអ្នកនូវ៖

- លេខនៃការណាត់ជួប។
- អាជ្ញាបណ្ណបើកបរពីបរទេសរបស់លោកអ្នក និងសេចក្តីបកប្រែបើមានការតម្រូវ(សូមមើលផ្នែកបកប្រែអាជ្ញាបណ្ណបើកបរ)។
- រថយន្តមួយគ្រឿងដែលអាចដំណើរការនិងមានលក្ខណៈអាចបើកបរបាន(VicRoads មិនផ្តល់រថយន្តសម្រាប់ការធ្វើតេស្តនោះទេ)។
- ប្រាក់សម្រាប់បង់ថ្លៃអាជ្ញាបណ្ណបើកបរ។

## ក្រោយពីការធ្វើតេស្តបើកបរ

មន្ត្រីធ្វើតេស្តអាជ្ញាបណ្ណបើកបរនឹងផ្តល់ជូនលោកអ្នកនូវមតិវាយតម្លៃថាតើលោកអ្នកជាប់ឬធ្លាក់។

### នៅពេលដែលលោកអ្នកជាប់តេស្តបើកបរលើផ្លូវថ្នល់

គេនឹងណែនាំឲ្យលោកអ្នកទៅកន្លែងថតរូបដើម្បីថតរូបលោកអ្នកសម្រាប់ធ្វើអាជ្ញាបណ្ណឲ្យលោកអ្នក។ អាជ្ញាបណ្ណលោកអ្នកនឹងទៅដល់ប្រអប់សំបុត្រលោកអ្នកតាមប្រៃសណីយ៍ក្នុងរវាងពេលប្រហែលជាមួយអាទិត្យ។ លោកអ្នកនឹងទទួលវិក្កយបត្រនៃការបង់ថ្លៃអាជ្ញាបណ្ណបើកបរ ដែលលោកអ្នកអាចប្រើបានរហូតដល់ពេលដែលអាជ្ញាបណ្ណបើកបរថ្មីរបស់លោកអ្នកទៅដល់។

VRPIN02900 How to get your Victorian Driver Licence – Khmer Authorised by VicRoads, 60 Denmark Street, Kew, 3101

vicroads

State Government Victoria